# ថ្វាយបង្គំសុំសេចក្តីសុខ

## ឥច្ចេវមច្ចន្ត នមស្សនេយ្យំ នមស្សមានោ រតនត្តយំ យំ

## បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ តស្សានុភាវេន ហតន្តរាយោ

ខ្ញុំសូមនមស្សការ លើកហត្ថាឱនសិរសី
បង្គំគុណទាំងបី ខ្ពស់លើសលប់ត្រៃលោកា ។
សូមបុណ្យកងកុសល ឱ្យបានដល់យើងខ្ញុំណា
ពេញពោរស្មើធារា ដូចជលសាធំទូលាយ ។
សូមឱ្យកំចាត់បង់ អពមង្គលទាំងឡាយ
ឱ្យចៀសចេញចាកឆ្ងាយ ក្តីអន្តរាយកុំបីមាន ។
ដោយកម្លាំងអានុភាព បុញ្ញលាភជាប្រធាន
កងបុញ្ញរាសីមាន សូមបានក្សាន្តកុំមានមោះ ។
ដោយគុណនមស្សការ ត្រៃរតនាប្រសើរខ្ពស់
សូមអានិសង្សនោះ ដាក់ដល់ឋាននិព្វានហោង ។



ដកស្រង់និងចងក្រងដោយខ្ញុំបាទ **ម៉ាន់ អ៊ុខ** អាចារ្យទី១សម្រាប់វត្តធម្មរាម ក្រុងស្តុកតុន រដ្ឋកាលីហ្វរនីញ៉ា ព.ស.២៥៤៣
វាយចម្លងដោយនាងខ្ញុំ ប៉ុក សារ៉ង ថ្ងៃទី២៦ ខែមីនា គ.ស.២០១២ * ពិនិត្យហើយនិងដាក់គេហទំព័រវត្តដោយខ្ញុំបាទ អ៊ិន លី

វត្តធម្មរាម
វត្តធម្មរាម